**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

## ស្តីពីការព្យួរការងារកិច្ចសន្យាការងារ

## នៅក្នុងក្រុមហ៊ុនធី&ខេ ហ្គាមេន អុិនដាស្រ្ទី ខូអិលធីឌី

នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២២ វេលាម៉ោង០៩និង០៥នាទី នៅក្នុងក្រុមហ៊ុនធី&ខេ ហ្គាមេន អុិនដាស្ត្រី ខូអិលធីឌី ដែលមានអាស័យដ្ឋានស្ថិតនៅភូមិទួលពង្រ សង្កាត់ចោមចៅ១ ខ័ណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ មានការប្រជុំមួយស្តីអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករ-និយោជិត ។

### ១. សមាសភាពអ្នកចូលរួម

#### ក. ភាគីក្រុមហ៊ុន

- លោកស្រី សួង សោភ័ណ្ឌ ប្រធានរដ្ឋបាល
- លោក គិន វដ្ឋា ជំនួយការរដ្ឋបាល
- លោក លី ឌីវ៉ាសនា លេខាកត់ត្រា

#### ខ. ភាគីខាងកម្មករ និយោជិត

- សហជីពប្រចាំមូលដ្ឋាន
- តំណាងកម្មករ និយោជិត
- ប្រធានក្រុម

### ២.ខ្លឹមសារអង្គប្រជុំ

ដោយសារការឆ្លងកាត់ដំណាក់កាលនៃការរាតត្បាតរបស់ជំងឺកូវីត-១៩ រហូតមកដល់បច្ចុប្បន្នបានធ្វើឲ្យក្រុមហ៊ុនបានជួបប្រទះវិបត្តិក្នុងដំណើរការផលិតកម្មយ៉ាងធ្ងន់ធ្ងរ ហើយសំខាន់ទៅទៀតនោះគឺក្រុមហ៊ុនពុំមានការបញ្ជាទិញដែលជាហេតុផលចាំបាច់តម្រូវឲ្យមានមានការព្យួរកិច្ចសន្យាការងាររយៈពេលពីរខែជាប់គ្នា ។

### ៣.លទ្ធផលអង្គប្រជុំ

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយសន្តិវិធី និងប្រកបដោយការយោគយល់គ្នា ដោយផ្តល់ឲ្យភាគីនីមួយៗមានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្តែងដោយទាំងភាគីខាងក្រុមហ៊ុន និងសហជីពប្រចាំមូលដ្ឋាន តំណាងកម្មករនិយោជិត និងប្រធានក្រុមបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ក្រុមហ៊ុនចាប់ផ្តើមព្យួរកិច្ចសន្យាការងារកម្មករ-និយោជិត ផ្នែកតុកាត់ ផ្នែកដេរ ផ្នែកពិនិត្យគុណភាព(QC) ផ្នែកសាប់ ផ្នែកតិ ផ្នែកជាងម៉ាស៊ីន ផ្នែកអនាម័យ ចំនួន៦៨៩នាក់ ស្រី ៥៣៦នាក់ក្នុងចំណោមកម្មករ-និយោជិត សរុបចំនួន១០៥៣នាក់ (ស្រី ៨៨០នាក់) ដោយគិតចាប់ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២៣ ។

៣-ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិត ចំនួន ២៧ដុល្លារ ក្នុង១ខែ អំឡុងពេលព្យួរកិច្ចសន្យាការងារ ។

CamScanner

៤-ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភផ្តាច់ជូនកម្មករ-និយោជិតម្នាក់ៗ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ចំនួន៥៨ដុល្លារ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២២ ។

៥-ក្នុងករណីដែលក្រុមហ៊ុនមានភាពប្រសើរឡើងវិញ ហើយមានការងារធ្វើក្នុងកំឡុងពេលព្យួរ នោះក្រុមហ៊ុននឹងអនុញ្ញាតិអោយកម្មករ-និយោជិតចូលធ្វើការមុនពេលកំណត់ ។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១០និង២០នាទីព្រឹកនាថ្ងៃដដែលក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខា រឺស្នាមមេដៃក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

ថ្ងៃច័ន្ទ ១១រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ត្រូវនឹងថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០២២

**ស្នាមមេដៃ**

**តំណាងសហជីព តំណាងកម្មករ**

**ហត្ថលេខា**

**ប្រធានរដ្ឋបាល**

**ហត្ថលេខា**

**លេខាកត់ត្រា**